ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៥៨　　　　　　តាងនាមប្រជារាស្ត្រខ្មែរ

ចុះថ្ងៃទី១៩-០៨-១៩៩៩　　　　　　តុលាការកំពូល

សាលដីកា

លេខ: ១៧　　　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១០ខែឧសភា

ចុះថ្ងៃទី១០-០៥-២០០០　　　　　　ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ　　ជាប្រធាន

២- លោក ឈឹម លីផល　　ជាចៅក្រម

៣- លោកប្រាក់ គឹមសាន　　ជាចៅក្រមរបាយការណ៍

៤- លោក ស៊ិន ទឹម　　ជាចៅក្រម

៥- លោក ជីវ កេង　　ជាចៅក្រម

លោក ទ៉ាន់ ចូរ៉ាត　　ជាក្រឡាបញ្ជី

តំណាងមហាអយ្យការលោក ម៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៧១ចុះថ្ងៃទី២៦ខែមិនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៥៨ ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

ពីបទ: ប៉ុនប៉ងធ្វើមនុស្សឃាត ប្រព្រឹត្តកាលពីថ្ងៃទី១៦-១២-១៩៩៦ នៅក្រុងភ្នំពេញ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១- ជនជាប់ចោទឈ្មោះ ម៉ិន ធា "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីលំនៅបច្ចុប្បន្នផ្ទះលេខ ៦២អឺ០ ផ្លូវលេខ១៨៤ ក្រុមទី២៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ ម៉ឹង ម៉ិន "រស់" ម្តាយឈ្មោះ ទឹម ផល្លា "រស់" នៅលើវ គេចខ្លួន ទោសពីមុនគ្មាន ។

- មេធាវីលោកអ៊ឹត ភុំ

២ - ជនជាប់ចោទឈ្មោះ ធិន ផារី " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុសអាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីលំនៅសព្វថ្ងៃផ្ទះលេខ ៦២អ៊ី០ ផ្លូវលេខ ១៨៤ ក្រុមទី២៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ កូនឈ្មោះ ចឹង ធិន " រស់ " ម្តាយឈ្មោះ ខែ វណ្ណា " រស់ " នៅឡើយ ។ គេចខ្លួន ទោសពីមុនគ្មាន ។

- មេធាវីលោក អ៊ុត ភុំ

៣ - ជនរងគ្រោះឈ្មោះ ហុង ហ៊ាន " ជាចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៤៩ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ មានទីលំនៅផ្ទះលេខ ៣១អ៊ី២ ផ្លូវលេខ១១៥ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

- មេធាវី គ្មាន

- តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ ហុង ហ៊ាន ឆ្លើយថា: ថ្ងៃទី ១៦-១២-១៩៩៦ ម៉ោង៧ព្រឹក ពេលទៅដល់តូបលក់ដូរផ្សារកណ្តាល ស្រាប់តែឈ្មោះ ចឹង ធិន បានស្រែកជេរប្រមាថ មកលើរូបខ្លួនដោយចោទថា ខ្លួនទាមទារតូបរបស់គាត់ តែខ្លួនពុំបានដឹងឡើយ ក៏មានការទាស់សំដីគ្នា ពេលនោះឈ្មោះ ចឹង ធិនបានស្ទុះមកដាល់ប្រពន្ធខ្លួនឈ្មោះ លី លាន បណ្តាលអោយជាំភ្នែកស្តាំ ខ្លួនពុំតបវិញឡើយ ប្រធានផ្សារក៏ឃាត់ទៅ ។ លុះម៉ោង ៩.៣០នាទីយប់ថ្ងៃដដែលស្រាប់តែឈ្មោះធិន ធា និងឈ្មោះ ធិន ផារី បានចូលទៅលួចវាយសម្លាប់រូបខ្លួននៅតាមផ្លូវទៀងតែម តែអ្នកទាំងពីរពួនចាំសម្លាប់ជាស្រេច ។ ពេលខ្លួនជិះម៉ូតូចូលទៅបានប្រហែលពីរម៉ែត្រពីជញ្ជាំង ឃើញឈ្មោះ ធិន ធា និង ធិន ផារី កំពង់ចាំស្ទាក់វាយរូបខ្លួន ដោយឈ្មោះ ធិន ធា កាន់បំពង់ទឹក វាយលើក្បាលរបស់ខ្លួនបណ្តាលអោយបែកក្បាលចេញឈាមយ៉ាងច្រើន គឺដេរចំនួន៥ថ្នេរ ។ ឈ្មោះ ធិន ផារី ជាអ្នកចាប់ខ្លួនជាប់ អោយឈ្មោះ ធិន ធា ជាអ្នកវាយលើក្បាលរបស់ខ្លួនថែមទៀត រហូតខ្លួនសន្លប់បាត់ស្មារតី ពេលនោះមានគេស្រែកសោទ្យារឡើងទើបឈ្មោះ ធិន ធា និង ធិន ផារី រត់ឡើងជិះម៉ូតូទៅបាត់ទៅ ។ ខ្លួនសំរាកពេទ្យរយៈពេល ១៤ ថ្ងៃ ។ ក្នុងរឿងនេះខ្លួនសុំអោយផ្តន្ទាទោសជនល្មើស និងសុំទាមទារជំងឺចិត្ត ៤.០០០ដុល្លារអាមេរិក ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ បានសំរេចចោទប្រកាន់លើឈ្មោះ ធិន ផារី ភេទប្រុស អាយុ ២៨ឆ្នាំ , ឈ្មោះធិន ធា ភេទប្រុស អាយុ-១៨ឆ្នាំ ពីបទ ប៉ុនប៉ងធ្វើឃាត ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៦-១២-៩៦ បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក" ចុះថ្ងៃទី០៨-១២-១៩៥៧ របស់តុលាការក្រុងភ្នំពេញដែលបានសំរេច :

១-ក : ផ្តន្ទាទោសឈ្មោះ ធិន ធា ភេទប្រុស អាយុ១៨ឆ្នាំជាតិខ្មែរដាក់ពន្ធនាគារកំណត់ចំនួន០៣ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន១៥ថ្ងៃគិតពីថ្ងៃទី២៤-១១-៥៧ ទោសសល់ពីនេះត្រូវព្យួរទាំងអស់ដោយទុករយៈពេលសាកល្បងចំនួន០៥ឆ្នាំ ។

ខ : ផ្តន្ទាទោសឈ្មោះ ធិន ដារី ភេទប្រុស អាយុ ២៨ ឆ្នាំជាតិខ្មែរដាក់ពន្ធនាគារកំណត់ចំនួន០១ឆ្នាំតែទោសនេះត្រូវព្យួរទាំងអស់ដោយទុករយៈពេលសាកល្បងចំនួន០៥ឆ្នាំ។ ពីបទ ប៉ុនប៉ងធ្វើឃាតដល់ជនរងគ្រោះឈ្មោះ ហុង ហ៊ាន ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៦-១២-១៩៥៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រាទី៣២,៦៨និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់អោយឈ្មោះ ធិន ដារី និងធិន ធា រួមគ្នាសងថ្លៃថ្នាំពេទ្យព្យាបាលនិងជំងឺចិត្ត ចំនួន៣.០០០ដុល្លារដល់ជនរងគ្រោះឈ្មោះ ហុង ហ៊ាន ។ សំណូមពរលើសពីនេះបដិសេធចោល ។ ក្នុងករណីទណ្ឌិត ធិន ដារី និង ធិន ធា មិនព្រមសងធនទណ្ឌខាងលើត្រូវចាប់ដាក់គុកបង្ខំរូបកាយទារធនទណ្ឌម្នាក់ៗ២ឆ្នាំ តាមមាត្រាទី៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះ សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥៤ "ក" ចុះថ្ងៃទី១៧-១២-៥៧ របស់ឈ្មោះធឹង ធិន ធិន ដារី និង ធិន ធា ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ១៥៥ "ក" ចុះថ្ងៃទី០៨-១២-១៩៥៧ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី៣នៃសាលក្រម ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ ធិន ធា និងឈ្មោះ ធិន ដារី ចុះថ្ងៃទី ១៧-១២-១៩៥៧ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោល ដោយផ្ទុយនិងគតិច្បាប់ ។

២-តម្កល់ចំណុចទី៣នៃសាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក" ចុះថ្ងៃទី០៨-១២-១៩៥៧ របស់តុលាការក្រុងភ្នំពេញទុកជាបានការ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៧១ចុះថ្ងៃទី ២៦-០៣-១៩៩៨ របស់សាលា-ឧទ្ធរណ៍ដែលបានសំរេចៈ

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧-១២-១៩៩៧ របស់ឈ្មោះ ចឹង ធិន , ធិន ដារី និង ធិន ធា ត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សេចក្តីសំរេចឃុំបទី២នៃសាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក" ចុះថ្ងៃទី០៨-១២-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទទាំងពីរនាក់និងដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី០៦-០៥-១៩៩៨ របស់ឈ្មោះចឹង ធិន ធិន ដារី និងធិន ធា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៧១ចុះថ្ងៃទី២២-០៣-១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី០៧-០៩-១៩៩៨ របស់ឈ្មោះធិន ធា និងធិន ដារី ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី០៤-១០-១៩៩៨ របស់ឈ្មោះហុង ហ៊ាន ជាចុងបណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា រឿងនេះតុលាការថ្នាក់ក្រោមសំរេចចោទប្រកាន់ជនល្មើសពីបទប៉ុនប៉ងធ្វើមនុស្សឃាដ ប៉ុន្តែការសំរេចដាក់ទណ្ឌកម្មវាផ្ទុយពីការចោទប្រកាន់ក្នុងរឿងឧក្រិដ្ឋ ធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរទៅនិងគតិច្បាប់ ។ យល់ឃើញថាអំពើល្មើសនេះពុំមានលក្ខណៈជាបទល្មើសប៉ុនប៉ងធ្វើមនុស្សឃាដឡើយគឺជាបទល្មើសបង្ករបួសស្នាមតែប៉ុណ្ណោះ ។ មហាអយ្យការអមតុលាការកំពូលសូមធ្វើសេចក្តីសន្និដ្ឋានជូនក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- បណ្តឹងសាទុក្ខរបស់ឈ្មោះ ចឹង ធិន , ធិន ដារី និង ធិន ធា ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

២- បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៧១ចុះថ្ងៃទី ២៦-០៣-១៩៩៨ របស់សាលាឧទ្ធរណ៍ទុកជាអសារឥតការ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ធិន ធា ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះ ថា៖ បានជាខ្ញុំប្តឹងសាទុក្ខព្រោះឈ្មោះ ហុង ហ៊ាន ទាមទារសំណងច្រើនពេក ម្យ៉ាងទៀតក្នុងរឿងនេះគាត់ក៏បានវាយបំផ្លាញសំភារៈលក់ដូររបស់ម្តាយខ្ញុំខូចខាតអស់ច្រើនដែរ ហេតុនេះសូមតុលាការពិនិត្យពិចារណា ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ធិន ផាលី ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះ ថា៖ ក្នុងរឿងនេះឈ្មោះ ហុង ហ៊ាន ជាអ្នកផ្តើមជំលោះមុន គាត់បានធ្វើអោយខូចខាតសំភារៈលក់ដូររបស់ម្តាយខ្ញុំមួយចំនួនដែរ ខ្ញុំគ្មានចេតនាវាយគាត់ទេ សូមតុលាការមេត្តាពិនិត្យពិចារណា ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ធិន ចឹង ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះ ថា៖ ខ្ញុំបាទក៏យល់ឃើញដូចកូនដែរ ហេតុនេះសូមតុលាការពិចារណាអំពីសំណងផង ។

- បានស្តាប់ចម្លើយដោះសាររបស់ឈ្មោះ ហុង ហ៊ាន ជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះ ថា៖ ចំពោះចម្លើយរបស់ជនជាប់ចោទគឺជាការឆ្លើយដោះសារ ជនជាប់ចោទបានទៅរងចាំវាយខ្ញុំជាមុន ៗ រឿងដំបូងគឺឈ្មោះ ចឹង ធិន បានចោទថាខ្ញុំបាទនោមដាក់តូបគាត់ ហើយក៏ឈ្លោះពាក្យសំដីគ្នានៅក្នុងផ្សារ ឈ្មោះ ចឹង ធិន បានវាយប្រពន្ធខ្ញុំបាទ ហើយបានអ្នកជិតខាងនិងសន្តិសុខផ្សារមកឃាត់ ហើយក៏បែកគ្នារៀងៗខ្លួនទៅ ។

- មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថា៖ ក្នុងរឿងនេះដំបូងគឺវាយគ្នាទៅវិញទៅមក ហើយមានរបួសរៀងៗខ្លួន។ ឯជនជាប់ចោទពេលត្រឡប់មកពីរៀនក៏ទៅផ្សារហើយបានដឹងថាម្តាយឪពុកខ្លួនឈ្លោះគ្នាជាមួយឈ្មោះ ហុង ហ៊ាន ហើយត្រូវទទួលរងរបួស បានទៅមន្ទីរពេទ្យអស់ហើយ ក្រោយមកជនជាប់ចោទបានទៅសួរនាំឈ្មោះ ហុង ហ៊ាន អំពីរឿងហេតុនេះ ៗ ជនជាប់ចោទពុំមានបំណងទៅវាយសម្លាប់ជនរងគ្រោះទេ ៗ ម្យ៉ាងទៀតការសំរេចរបស់តុលាការថ្នាក់ក្រោមអំពីសំណងនោះគឺវាមានកំរិតខ្ពស់ណាស់ កូនក្តីខ្ញុំគ្មានលទ្ធភាពសងទេ សូមតុលាការពិចារណា ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៩ចុះថ្ងៃទី០៦-០៥-១៩៩៩ របស់ឈ្មោះ ចឹង ធិន ធិន ផានី និង ធិន ធា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ធិន ធា និង ធិន ផានី ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី១៦-១២-៩៦ ប្រាក់ជ័រមែន ហើយត្រូវបានតុលាការក្រុងភ្នំពេញ សំរេចផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់ ក្រោមអប្បបរិមានៃទោស ព្រមទាំងព្យួរទោសដោយអនុវត្តក្នុងពន្ធនាគារតែ១៥ថ្ងៃ ។ ប៉ុន្តែសាលក្រមនេះពុំត្រូវបានព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ទេ។ ដូច្នេះសាលាឧទ្ធរណ៍ក៏ដូចជាតុលាការកំពូលដែរពុំមានសមត្ថកិច្ចទុកជាមោឃៈបានឡើយ ។

- យល់ឃើញថា កាលដែលជនជាប់ចោទនិងមេធាវីជនជាប់ចោទលើកឡើងនាពេលសវនាការនេះថា ជនជាប់ចោទពុំមានចេតនាប៉ុនប៉ងធ្វើមនុស្សឃាតទេគឺគ្រាន់តែទៅសួរនាំរកខុសត្រូវនោះជាការពុំត្រឹមត្រូវទេ ពីព្រោះអង្គហេតុនៃរឿងនេះបញ្ជាក់អោយឃើញថា ជនជាប់ចោទពិតជាបានកាន់បំពង់ទីបទៅពួនស្ទាក់ចាំវាយឈ្មោះហុង ហ៊ាន ប្រាក់ជ័រមែន ។

- យល់ឃើញថាការដែលជនជាប់ចោទនិងមេធាវីជនជាប់ចោទលើកឡើងនាពេលសវនាការនេះថាតុលាការអោយសង៣.០០០ដុល្លារអាមេរិកជាការធ្ងន់ធ្ងរពេកណាស់នោះ តុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាបានឡើយពីព្រោះ តុលាការកំពូលជំនុំជំរះពេលនេះតែលើអង្គច្បាប់ប៉ុណ្ណោះ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៣១ចុះថ្ងៃទី២៦-០៣-១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងអំពីការផ្តន្ទាទោសក្រោមអប្បបរិមានៃទោសនិងអនុវត្តទោសព្យួរ ប៉ុន្តែតុលាការកំពូលពុំមានសមត្ថកិច្ចទុកជាមោឃៈបានទេពីព្រោះគ្មានបណ្តឹងឧទ្ធរណ៍និងសាទុក្ខពីដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការ និង មហាអយ្យការ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ០៦-០៥-១៩៩៩ របស់ឈ្មោះ ចឹង ធិន ធិន ផានី និង ធិន ធា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧១ ចុះថ្ងៃទី ២៦ - ០៣ - ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០០ ។